## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២០ ខែ មិនា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៩៩,២២១ ដុល្លារអាមេរិក សម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពកំពែង



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុននឹងផ្តល់ទឹកប្រាក់សរុបចំនួន ៩៩,២២១ដុល្លារអាមេរិកដល់មន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់សម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពកំពែង។កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយលោក កាវ៉ាម្ង៉ា ហ៊ីរ៉ូស៊ី ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក កែវ វ៉ៃ ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់នៅស្ថានទូតជប៉ុន។



ជាមួយជំនួយឧបត្ថម្ភនេះ ប្រព័ន្ធស្រោចស្រពកំពែងនឹងត្រូវបានជួសជុលដោយមន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់។ គម្រោងនេះរួមបញ្ចូលការស្តារប្រឡាយកម្រិត២មួយខ្សែដែលមានប្រវែង ២,១០០ម៉ែត្រ និងការសាងសង់លូទឹកបញ្ចូលស្រែ៤កន្លែង សំណង់ស្នាក់ទឹក២កន្លែង និងប្រឡាយកម្រិត២ថ្មីមួយខ្សែដែលមានប្រវែង ១,០៥០ម៉ែត្រ។ យើងរំពឹងថា វានឹងកាត់បន្ថយផលប៉ះពាល់ពីទឹកជំនន់ដែលកើតមានឡើងជារៀងរាល់ឆ្នាំ និងសម្រួលដល់ការងារស្រោចស្រពរបស់ប្រជាកសិករប្រមាណ៤៩១គ្រួសារនៅក្នុងតំបន់។ ដោយមានជំនួយផ្នែកបច្ចេកទេសពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តបាត់ដំបង ប្រជាសហគមន៍នឹងថែទាំប្រព័ន្ធស្រោចស្រពនេះឲ្យមានសភាពល្អជានិច្ច។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៤៧លានដុល្លារអាមេរិកដល់អាជ្ញាធរមូលដ្ឋាននិងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៤៧០គម្រោងនៅទូទាំងប្រទេស។



---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីមែល: [eco.jpn@.pp.mofa.go.jp](mailto:eco.jpn@.pp.mofa.go.jp)*
*គេហទំព័រ: http://www.kh.emb-japan.go.jp*